**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
លេខ ០១៦ សហវ.

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល លេខ 097
ថ្ងៃ 03.12.2015
ម៉ោង 10h00

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១៥

# សារាចរណែនាំ
## ស្តីពី
## ការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៥

យោងមាត្រា១៨នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ប្រការ៣២ និងប្រការ៣៣ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ មាត្រា២៧ នៃអនុក្រឹត្យលេខ ១៧២ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ និងមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេសស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៥ ដូចខាងក្រោម ៖

១. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក មេឃុំ ដែលជាអាណាប័កដើមខ្សែ និងអភិបាលនៃគណៈអភិបាលខណ្ឌ ចៅសង្កាត់ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវខិតខំជំរុញការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មកបង់ចូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ។ ប្រសិនបើមានការយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគាររាជធានី ខេត្ត ត្រូវកត់ត្រាចូលជាចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៦។

២. ការស្នើសុំឧបត្ថម្ភតុល្យភាពថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។

៣. ការធ្វើនិយ័តភាពឥណទានថវិកាដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។ ចំពោះការធ្វើនិយ័តភាពឥណទានថវិការដ្ឋបាលក្រុង ស្រុក ដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីរដ្ឋបាលខេត្តសាមីជាអ្នកសម្រេច រដ្ឋបាលក្រុង ស្រុក ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមករដ្ឋបាលខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤
Phone : 855-23-724 664
ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Fax: 855-23-427 798

៤. រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការបើកផ្តល់សាច់ប្រាក់រង្វទេយ្យបុរេប្រទានជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចុងក្រោយបង្អស់នៅម៉ោង ១៧ និង៣០នាទីនាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។ រង្វទេយ្យករបុរេប្រទានត្រូវប្រមូលឯកសារ និងលិខិតយុត្តិការចំណាយរួចបោះផ្សាយអាណត្តិនិយ័តកម្មដោយឆ្លងទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឬមន្ត្រីត្រួតពិនិត្យថវិកា (ឃុំ សង្កាត់ពុំចាំបាច់ឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ រួចបញ្ជូនទៅរតនាគាររាជធានី ខេត្តឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ជាកំហិត។ ចំពោះការផ្តល់ប្រាក់បុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ហើយការទូទាត់ប្រាក់បុរេប្រទាននេះ ត្រូវរួសរាន់ប្រមូលឯកសារស្នើសុំការទូទាត់ឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ចំពោះសាច់ប្រាក់រង្វទេយ្យបុរេប្រទាន និងប្រាក់បុរេប្រទាន ដែលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានចំណាយនៅសល់ ត្រូវយកមកបង់នៅរតនាគាររាជធានី ខេត្ត មិនឲ្យហួសថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

៥. រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅម៉ោង ១៧ និង៣០នាទី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ដូច្នេះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ (អាណត្តិបើកប្រាក់សម្រាប់ទូទាត់ត្រង់ អាណត្តិបើកប្រាក់សម្រាប់ទូទាត់រង្វទេយ្យបុរេប្រទាន) ដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ចុះហត្ថលេខា រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត ឲ្យបានមុនម៉ោង ១៧ និង៣០នាទី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

៦. នៅចុងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រតនាគាររាជធានី ខេត្ត ត្រូវផ្ទេរសមតុល្យគណនីចំណូលចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទ។

- ចំពោះរដ្ឋបាលរាជធានី ខេត្ត ប្រសិនបើមានអតិរេកថវិកា រតនាគាររាជធានី ខេត្ត ត្រូវជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្ត ឲ្យធ្វើសលាកប័ត្រចំណូលបង់ប្រាក់ចូលថវិការដ្ឋឆ្នាំ២០១៥ ជាបន្ទាន់។ ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅចន្លោះពីថ្ងៃទី០១ ដល់ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ នោះកាលបរិច្ឆេទនៃការបង់ចំណូលត្រូវកត់ត្រាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ផ្ទុយទៅវិញប្រសិនបើហួសកាលកំណត់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ រដ្ឋបាលរាជធានី ខេត្ត នៅតែពុំទាន់បានបង់ចំណូលនោះទេ គឺរតនាគាររាជធានី ខេត្ត ត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិការដ្ឋ ហើយត្រូវជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្ត ឲ្យបានជ្រាបជារបាយការណ៍។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកថាជាកិច្ចប្រតិបត្តិការថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែរ។ ចំពោះការបង់សំណៃសចំណាយក្រោយថ្ងៃទី៣១ ខែធ្នូ នៃកាលបរិច្ឆេទ ត្រូវបានចាត់ទុកជាចំណូលថវិកានៃកាលបរិច្ឆេទសម្រាប់ឆ្នាំថ្មី និងកត់ត្រាចូលជាចំណូលថវិកាគណនី៧៦៩៨ (ផលហិរញ្ញវត្ថុផ្សេងៗ)។

- ចំពោះរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បើសិនមានអតិរេកថវិកា រតនាគាររាជធានី ខេត្ត ត្រូវជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ អំពីចំនួនតួលេខអតិរេកថវិកា ដើម្បីឲ្យរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ យកអតិរេកនេះ កត់ត្រាចូលក្នុងគណនីមូលនិធិបម្រុងដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាននៃថវិកាឆ្នាំបន្ទាប់។ ចំពោះថវិកាដែលមានប្រភពពីដៃគូអភិវឌ្ឍន៍ដូចជា អង្គការ SIDA អង្គការ UNICEF អង្គការ UNCDF និងថវិកាមានប្រភពពីថវិការដ្ឋតាមរយៈការផ្ទេរមុខងាររបស់ក្រសួងសាមី ដូចជា សេវាអនាម័យបរិស្ថាន ការជួសជុលថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅជនបទ ដែលនៅពុំទាន់បានប្រើប្រាស់ថវិកាអស់ ត្រូវបានយោងបន្តនិងកត់ត្រាជាចំណូលថវិកាឆ្នាំបន្ទាប់។

- ដោយឡែកអតិរេកថវិកាសង្កាត់ចំណុះរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង មិនត្រូវបញ្ចូលទៅក្នុងអតិរេកថវិការបស់រដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងសាមីឡើយ។ ប៉ុន្តែចំពោះអតិរេកថវិការបស់រដ្ឋបាលខណ្ឌ (បើមាន) គឺត្រូវបញ្ចូលទៅក្នុងអតិរេកថវិការបស់រដ្ឋបាលរាជធានី។



ﾅ

៧. ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ សម្រាប់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឆ្នាំ២០១៥ ត្រូវបន្តរហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦។ ប្រតិបត្តិការនេះ ត្រូវបានពិនិត្យ និងកត់ត្រាជាលេខនាបន្ថែមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលទាក់ទងទៅនឹង ៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬ នៃចំណាយថវិកា ដែលបានពិនិត្យកត់ត្រាជាលេខនា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ជាអាទ៏ចូលគណនីកត់ត្រាបណ្តោះអាសន្ន។

- អាណត្តិនិយ័តកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យករបុរេប្រទានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ការកែតម្រូវលេខនាខុស។

៨. ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការិយបរិច្ឆេទឆ្នាំ២០១៦ ត្រូវកត់ត្រាចូលក្នុងគណនីថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឆ្នាំ២០១៦។

៩. ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងស្មៀនឃុំ សង្កាត់ ត្រូវដំណើរការបូកសរុប និងផ្ទៀងផ្ទាត់តួលេខនៃការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឆ្នាំ២០១៥ ជាមួយរតនាគាររាជធានី ខេត្ត រួចផ្ញើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យបានមុនថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦។ រតនាគាររាជធានី ខេត្ត ត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ រីឯរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍បូកសរុបចំណូល ចំណាយថវិការបស់រដ្ឋបាលរបស់ខ្លួន តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

- រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលខណ្ឌ ដូចមានគំរូតារាងឧបសម្ព័ន្ធក៥ និងខ៥ ជូនភ្ជាប់មកជាមួយ។

- ចំពោះរដ្ឋបាលក្រុង ត្រូវបូកបញ្ចូលការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលសង្កាត់ចំណុះក្រុង ដូចមានគំរូតារាងឧបសម្ព័ន្ធក៤ និងខ៤ ជូនភ្ជាប់មកជាមួយ។

- រដ្ឋបាលខណ្ឌ ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមករដ្ឋបាលរាជធានី ដើម្បីធ្វើការបូកសរុប។

- រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលរាជធានី និងរដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមករដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង។

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុប ដូចមានគំរូតារាងឧបសម្ព័ន្ធក៦ និងខ៦ ជូនភ្ជាប់មកជាមួយ។

- រតនាគាររាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ស្តីពីអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្តដើម្បីជាមូលដ្ឋានធ្វើការបូកសរុបការបិទបញ្ជីចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានគំរូតារាងឧបសម្ព័ន្ធក៦និងខ៦ និងក៧និងខ៧ ជូនភ្ជាប់មកជាមួយ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកាដោយភ្ជាប់មកនូវរបាយការណ៍បូកសរុបចំណូល ចំណាយថវិកា ដាក់ឆ្លងអង្គប្រជុំអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។ ក្រោយពីក្រុមប្រឹក្សាបានអនុម័តលើរបាយការណ៍បិទបញ្ជីថវិកាប្រចាំឆ្នាំ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ត្រូវអនុវត្តដូចខាងក្រោម៖

- ចំពោះអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាដោយមានភ្ជាប់នូវរបាយការណ៍បូកសរុបចំណូល ចំណាយថវិកាមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ២ច្បាប់ និងក្រសួងមហាផ្ទៃចំនួន ១ច្បាប់ (ច្បាប់ដើម)។

- មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំ និងឯកសារពាក់ព័ន្ធទាំងអស់ទៅអភិបាលនៃគណៈអភិបាលខេត្ត ដើម្បីបញ្ជាក់នីត្យានុកូលភាព រួចផ្ញើទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីបូកសរុបចំណូល ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ២ច្បាប់ និងក្រសួងមហាផ្ទៃចំនួន ១ច្បាប់ (ច្បាប់ដើម)។

- របាយការណ៍បិទបញ្ជីថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដើម្បីឲ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សម្រេចទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាជំពូកមួយ រួចដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ រតនាគាររាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តនិងសហការឲ្យបានត្រឹមត្រូវតាមការកំណត់ដូចខាងលើ ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុបនិងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និងរដ្ឋសភា ព្រឹទ្ធសភា ពិនិត្យអនុម័តឲ្យបានទាន់ពេលវេលា។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ក្រសួងមហាផ្ទៃ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

រាជធានី ខេត្ត: ......

លេខកូដ............

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងសរុបចំណូលថវិការដ្ឋបាលរាជធានី ខេត្ត...
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ក.១

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្ត ជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4=3 /2 | |
| | | | | | | | |
| | | | សរុបរួម | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ....

លេខកូដ...........

# តារាងសរុបចំណាយថវិការដ្ឋបាលរាជធានី ខេត្ត.....

# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ខ.១

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | | | |
| | | | 1 | 2 | 3 | 4 | 5 | 6=2+3+4-5 | 7 | 8=7/2 | 9=7-2 | |
| | | | | | | | | | | | | |
| | | | សរុបរួម | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត:....

ក្រុង ស្រុក ខណ្ឌ:....

លេខកូដ:....

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងសរុបចំណូលថវិកាក្រុង ស្រុក ខណ្ឌ
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ក.២

ឯកតាគិត:រៀល

| ជំពូក | មាត្រា | អនុមាត្រា | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | អនុវត្ត ជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4=3/2 | |
| | | | | | | | |
| | | | សរុបរួម | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត:....

ក្រុង ស្រុក ខណ្ឌ:....

លេខកូដ:....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងសរុបចំណាយថវិកាក្រុង ស្រុក ខណ្ឌ ...
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ខ.២

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | ចលនាឥណទាន | | | ឥណទាន អនុញ្ញាត | អនុវត្ត ជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | | | |
| | | | 1 | 2 | 3 | 4 | 5 | 6=2+3+4-5 | 7 | 8=7/2 | 9=7-2 | |
| | | | | | | | | | | | | |
| | | | សរុបរួម | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ហត្ថលេខានិងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត:....

ក្រុង ស្រុក ខណ្ឌ:....

ឃុំ សង្កាត់:....

លេខកូដ:....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងសរុបចំណូលថវិកាឃុំ... សង្កាត់....

# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ក.៣

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4=3/2 | |
| | | | | | | | |
| | | | សរុបរួម | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា
មេឃុំ ចៅសង្កាត់

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត:....

ក្រុង ស្រុក ខណ្ឌ:....

ឃុំ សង្កាត់:....

លេខកូដ:....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងសរុបចំណាយថវិកាឃុំ សង្កាត់...

# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ខ៣

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | | | |
| | | | 1 | 2 | 3 | 4 | 5 | 6=2+3+4-5 | 7 | 8=7/2 | 9=7-2 | |
| | | | | | | | | | | | | |
| | | | សរុបរួម | | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា

មេឃុំ ចៅសង្កាត់

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង

រាជធានី ខេត្ត:.....

ក្រុង.....

លេខកូដ....

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងបូកសរុបចំណូលថវិកាក្រុង... និងសង្កាត់ចំណុះ

តារាងឧបសម្ព័ន្ធ:ក៤

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | ក្រុង | សរុបសង្កាត់ | សរុបរួម | ក្រុង | សរុបសង្កាត់ | | | | |
| | | | 1 | 2=3+4 | 3 | 4 | 5 =6+7 | 6 | 7 | 8=5/2 | 9=6/3 | 10=7/4 | |
| | | | | | | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលក្រុង

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តៈ.....

ក្រុង..... ...

លេខកូដ....

# តារាងបូកសរុបចំណាយថវិកាក្រុង...និងសង្កាត់ចំណុះ
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធៈខ.៤

ឯកតាគិតៈរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | ឥណទានអនុញ្ញាត | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | ក្រុង | សរុបសង្កាត់ | សរុបរួម | ក្រុង | សរុបសង្កាត់ | សរុបរួម | ក្រុង | សរុបសង្កាត់ | | | |
| | | | 1 | 2=3+4 | 3 | 4 | 5=6+7 | 6 | 7 | 8=9+10 | 9 | 10 | 11=8/2 | 13=8/5 | |
| | | | | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលក្រុង

ហត្ថលេខានិងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

សាលារាជធានីភ្នំពេញ

លេខកូដ....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិកាសាលារាជធានី និងខណ្ឌចំណុះ

តារាងឧបសម្ព័ន្ធ:ក.៥

# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី | សរុបខណ្ឌ | សរុបរួម | រាជធានី | សរុបខណ្ឌ | | | |
| | | | 1 | 2=4+5 | 4 | 5 | 6=7+8 | 7 | 8 | 9=6/2 | 10=7/4 | 11=8/5 |
| | | | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
| អភិបាលនៃគណៈអភិបាលរាជធានី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី | ប្រធានរតនាគាររាជធានី | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

លេខកូដ:......

# តារាងបូកសរុបចំណាយថវិកាសាលារាជធានី និងខណ្ឌចំណុះ

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ខ.៥

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | | | ឥណទានអនុញ្ញាត | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី | សរុបខណ្ឌ | សរុបរួម | រាជធានី | សរុបខណ្ឌ | សរុបរួម | រាជធានី | សរុប ខណ្ឌ | | |
| | | | 1 | 2=3+4 | 3 | 4 | 5=6+7 | 6 | 7 | 8=9+10 | 9 | 10 | 11=8/2 | 12=8/5 |
| | | | | | | | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលរាជធានី

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី

ហត្ថលេខា

អ្នកធ្វើតារាង

រាជធានី ខេត្ត.........

ព្រះរាជាណាចក្រកម្ពុជា

លេខកូដ

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ក៦

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រ ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបឃុំ | សរុបសង្កាត់ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបឃុំ | សរុបសង្កាត់ | |
| | | | 1 | 2=3+4+5+6+7 | 3 | 4 | 5 | 6 | 7 | 8=9+10+11+12+13 | 9 | 10 | 11 | 12 | 13 | 14=8/2 |
| | | | | | | | | | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត.........

លេខកូដ

# តារាងបូកសរុបចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:១៦

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | | | ឥណទានអនុញ្ញាត | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រ ប្រៀបធៀប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | | |
| | | | 1 | 2=3+4+5+6+7 | 3 | 4 | 5 | 6 | 7 | 8=9+10+11+12+13 | 9 | 10 | 11 | 12 | 13 | 14=15+16+17+18+19 | 15 | 16 | 17 | 18 | 19 | 20=14/2 | 21=14/8 |
| | | | | | | | | | | | | | | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
| អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |

រាជធានី ខេត្ត:.....

ក្រុង.........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិកាឃុំ សង្កាត់ចំណុះរាជធានី និងសង្កាត់ចំណុះក្រុង

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ក៧

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4=3/2 | |
| | | | | | | | |

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត:.....

ក្រុង..... ...

# តារាងបូកសរុបចំណាយថវិកាឃុំ សង្កាត់ចំណុះរាជធានី និងសង្កាត់ចំណុះក្រុង

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

តារាងឧបសម្ព័ន្ធ:ខ៧

ឯកតាគិត:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=3/1 | 5=3/2 | |
| | | | | | | | | | |

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង